ដីកា ក្រៅ ច្បាប់

នៅស្រុកខ្មែរសព្វថ្ងៃ តុលាការ អាចកោះហៅ តំណាងរាស្ត្រ គ្រប់ករណី មិនចំបាច់ សូម អនុញ្ញាត ពី រដ្ឋសភា ដើម្បី លើកបំរាម ច្បាប់ ការពារ អភ័យឯកសិទ្ធិ របស់ តំណាងរាស្ត្រ ជាមុននោះ ឡើយ។ ពិតប្រាកដណាស់ ថា តំណាងរាស្ត្រ ម្នាក់ៗ មាន សេរីសម្រេច ដោយខ្លួនឯង ចូលខ្លួន តាម ដីកា របស់តុលាការ ដោយ មិនចាំបាច់ មាន ការលើកចោល អភ័យឯកសិទ្ធិ របស់ខ្លួន។

ដូចសព្វដង តុលាការ តែងតែ បំពាន ច្បាប់ ពាក់ព័ន្ធនឹង ដីកា កោះហៅ សមាជិកសភា។ ជួនកាល ជួបនឹង ការប្រកែក ពី អ្នកជាប់ចោទ ដូចយ៉ាង ករណី លោក កឹម សុខា ដែល គាត់ លើកយក អភ័យឯកសិទ្ធិ របស់គាត់ ជា តំណាងរាស្ត្រ មក ក្រាញនឹង ដីកា ដែល បណ្តា អោយមាន រិបត្តិនយោបាយ មួយរយៈ រវាង គណបក្សសង្គ្រោះជាតិ នឹង គណបក្សកាន់អំណាច នៅរដ្ឋសភា។ តែទោះបីយ៉ាងណាក្តី តុលាការ នៅតែ បន្ត បតក្តម[1] ហើយ កាត់ទោស ដោយ ទុដ្ឋភាព[2] លោក កឹម សុខា ដាក់ពន្ធនាគារ។ តែ ទោស នោះ លោក កឹម សុខា មិនព្រម

[1] បតក្តម ; បំពានច្បាប់ ; violation de la loi។

[2] កាត់ទោសដោយទុដ្ឋភាព ; jugement par contumace។

ដីកា ក្រៅ ច្បាប់

អនុវត្តវា រហូត គាត់ សូមឲព្រះមហាក្សត្រ លើកទោសចោល ហើយ បន្ទាប់មក មាន សំណើរ របស់ លោក ហ៊ុន សែន ថ្វាយទៅ ព្រះរាជា ក្នុង គោលដៅ ដូច្នោះដែរ។

ក្នុង ករណី តំណាងរាស្ត្រ មួរ សុខហួរ និង ទ្ឍង រ៉ី ដែល សុខចិត្ត ចូលខ្លួន ទៅ បំភ្លឺ អំពី ករណី អ្នកជាប់ចោទ ឈ្មោះ ហួត ឃីរ៉ុទ្ធី ហៅ ជុន ច័ន្ទបុត្រ តាម ដីកា តុលាការ ដោយមិនចាំបាច់ មាន ការស្នើ ទៅ រដ្ឋសភា ដើម្បី លើកចោល អភ័យឯកសិទ្ធិ របស់ ខ្លួន ជាមុនសិន វា ជា ករណី អាចសួរ ជា សំនួរ ថា បើ តុលាការ បំពានច្បាប់ ជាក់ស្តែង ហើយ អ្នកតែងច្បាប់ (législateur) មិនតវ៉ា ហើយ អនុវត្ត កិច្ចខុសច្បាប់នោះ ថែមទៀត តើ គេ អោយឈ្មោះ វា ជា អ្វី ? ឬក៏ ជា ការរួមគំនិតគ្នា ? ឬក៏ ជា ការ មិនយកចិត្តដាក់នឹង អយុត្តិធម៌ ? ឬក៏ ជា សេចក្ដីខ្លាច នៃ អំណាចផ្តាច់ការ ?

យើងដឹងថា អ្នកទាំងពីរ នោះ ជា អ្នកនយោបាយ មាន ការ ពិសោធន៍ លើឆាក នយោបាយ នៅស្រុកខ្មែរ។ គាត់ ស្គាល់ បរិយាកាស ក្ដៅ ត្រជាក់ ដូច្នេះ ប្រហែល ជា គាត់ អាច ឆ្លើយ តប សំនួរ ខាងលើ នេះបាន នៅក្នុងចិត្ត របស់គាត់ បើ គាត់ មិនចង់ និយាយ អោយឮខ្ជរខ្ជាយ។ តែ ការនៅស្ងៀម នោះ វា មាន សម្លេង របស់វា គឺ នរសត្តិសម្បជញ្ញៈ ដែល វា ខុសពី សត្ត ជា អត្តវិធា ងងឹត (espèce de moi obscur) ក្ខាន មានសោះ មន្ទ្រប្រកា សីលធម៌ (lueur morale) រស់នៅក្នុង ច្បាប់ នៃ សភា

ដីកា ក្រៅ ច្បាប់

រកតិ ដែលជា ផ្លូវជីវិត របស់ ធម្មជាតិ កំណត់ដោយកម្មវាសនា សំរាប់ ដើរ ឥតចាំបាច់ មាន វិចារណញ្ញាណ គឺថា អាត្ម (le moi) ក្នាន សេរីភាព អញ្ចឹង វា ក្នាន ការទទួលខុសត្រូវ នៅក្នុង ជីវិត របស់វា។

តែ លោកស្រី មូរ សុខហួរ និង លោក ឡង រី ជា អ្នកតែងច្បាប់ ដូច្នេះ ជា ជន មាន ការទទួលខុសត្រូវ នៅចំពោះមុខ កិច្ច (acte) របស់ខ្លួន ព្រោះ វា ជា អំពើ ជា ច្បាប់ ជា និមិត្តរូប នៃ យុត្តិធម៌ និង ជា សីលធម៌ ផង ដូច្នេះ នៅ ចំពោះមុខ អំពើណា ដែល បំពានច្បាប់ បើមិនយកច្បាប់ ឆ្លើយតបនោះទេ វា ជា ចម្លើយ ផ្ទុយនឹង គោលការណ៍ នៃ លទ្ធិប្រជាធិបតេយ្យ ព្រោះ អត្ថរស់ នៃ លទ្ធិប្រជាធិបតេយ្យ គឺ ការប្រឆាំងដាច់ខាតនឹង អំណាចផ្តាច់ការ ដែលតែងតែបំពានច្បាប់ ដើម្បីរក្សា អំណាច។

តទៅមុខ នៅស្រុកខ្មែរ មាន តុលាការ បំពានច្បាប់ មាន អ្នក តែងច្បាប់ គោរព ដីកា របស់ ចៅក្រម មិនចេះច្បាប់ ដូច្នេះ បើ ច្បាប់, នីតិ, ករណីកិច្ច, វិចារណញ្ញាណ, សុភនិច្ឆ័យ, សមធម៌, យុត្តិធម៌ ក្នានការគោរព ពី អ្នកតែងច្បាប់ និង តុលាការ តើ គេ អាច ទុក ស្រុកខ្មែរ ជា ស្រុកបែបណា ?

តែ នៅស្រុកខ្មែរ ការស្តាប់បង្គាប់ អំណាចផ្តាច់ការ ពីសំណាក់ អ្នកនយោបាយ ក្រប់មជ្ឈដ្ឋាន មិនសុទ្ធតែមកពីខ្លាច អំពើ ពិរុទ្ធាន នៃ អាជ្ញាធរ នោះឡើយ គឺ ភាគច្រើន វា មាន នៅក្នុង សតិសម្បជញ្ញៈ នៃ អត្តង្គត របស់ អ្នកចេះដឹង តែម្តង។